សួស្តីអ្នកទាំងអស់គ្នា បាទ ជួបគ្នាទៀតហើយក្នុងថ្ងៃនេះ ហើយថ្ងៃនេះយើងមានប្រធានបទមួយ ដើម្បីលើកយកមកនិយាយ ដែលប្រធានបទយើងដែលនឹងនិយាយនៅក្នុងថ្ងៃនេះ គឺការមុតដៃនឹងកាំបិត បាទ ការមុតដៃនឹងកាំបិត អញ្ចឹងពួកយើងមកមើលរូបភាពទាំងអស់គ្នាតែម្តង។

នៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញថា មានបុរសម្នាក់ មានអាយុគាត់ហ្នឹងប្រហែលជា ២០ ឆ្នាំ។ បាទ គាត់ពាក់អាវយឺតដៃខ្លីពណ៌លឿង បាទ គាត់ពាក់អាវយឺតដៃខ្លីពណ៌លឿង គាត់មានសក់ខ្មៅ ហើយគាត់កាត់សក់ខ្លី គាត់មើលទៅក្នុងរូបភាពនេះគឺគាត់នៅក្នុងផ្ទះបាយ បាទ គាត់នៅក្នុងផ្ទះបាយ ដោយសារតែគាត់កំពុងតែកាន់បន្លែនិងកំពុងតែចិតបន្លែដើម្បីធ្វើម្ហូប អញ្ចឹងយើងអាចនិយាយបានថា ពេលនេះគឺជាពេលដែលជិតញ៉ាំបាយហើយ ព្រោះគាត់កំពុងតែធ្វើម្ហូប យើងឃើញដៃឆ្វេងរបស់គាត់ ដៃឆ្វេងរបស់គាត់កំពុងតែកាន់កាំបិត រីឯដៃស្តាំកំពុងតែកាន់មើមការ៉ុតមួយ គាត់កំពុងតែចិតការ៉ុតនោះជាចំណិតតូចៗជាច្រើន អញ្ចឹងយើងឃើញនៅក្បែរកាំបិតនោះ គឺមានចំណិតការ៉ុតតូចៗជាច្រើន ដែលគាត់បានចិតរួច ហើយនៅលើតុក្បែរគាត់ផងដែរ គឺយើងមានឃើញបន្លែជាច្រើនផ្សេងទៀត ដែលគាត់ដាក់នៅក្បែរនោះ មានដូចជាមើមការ៉ុតមួយ មានដូចជាផ្លែប៉េងប៉ោះពីរ ខ្ទឹមបារាំង ក៏ដូចជាផ្លែម្ទេសប្លោកផងដែរ អញ្ចឹងគាត់ដាក់បន្លែផ្សេងៗជាច្រើននៅលើតុក្បែរដៃរបស់គាត់ ងាយស្រួលក្នុងការគាត់យកមកចិត ដើម្បីធ្វើម្ហូប ដើម្បីញ៉ាំជាមួយនឹងបាយ អញ្ចឹងបុរសនោះ គាត់កំពុងតែចិតបន្លែ ដើម្បីធ្វើម្ហូបក្នុងការញ៉ាំបាយ។

ចូលដល់រូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញថាបុរសដដែល គាត់កំពុងតែនៅក្នុងផ្ទះបាយ ហើយចិតបន្លែដូចមុនអញ្ចឹង អញ្ចឹងគាត់ចិតការ៉ុតមួយចំណិតទៅមួយចំណិតតូចៗជាច្រើន ដាក់នៅលើតុ ក៏ប៉ុន្តែនៅក្នុងរូបភាពទី ២ នេះ យើងឃើញថាបុរសនោះបានបើកភ្នែកធំៗ ហើយញញ្ជេញរបស់គាត់ចេញធ្មេញសស្វាចតែម្តង ព្រោះថាគាត់មានអារម្មណ៍ថា ហាក់ដូចជាឈឺយ៉ាងខ្លាំង ព្រោះនៅពេលដែលយើងឈឺ យើងនឹងបើកភ្នែកធំៗ ហើយញញ្ជេញធ្មេញដើម្បីសម្តែងអំពីការឈឺចាប់ អញ្ចឹងនៅក្នុងរូបភាពនេះ គឺបុរសនោះ គាត់បានចិតបន្លែ ហើយគាត់ពុំបានយកចិត្តទុកដាក់ទៅនឹងការងាររបស់គាត់ដែលកំពុងធ្វើនោះទេ បាទ គាត់ពុំបានយកចិត្តទុកដាក់នោះទេ អញ្ចឹងហើយធ្វើឲ្យដៃឆ្វេងរបស់គាត់ដែលកាន់កាំបិតនោះ ចិតត្រូវនឹងដៃរបស់គាត់ អញ្ចឹងធ្វើឲ្យគាត់មុតដៃ បាទ អញ្ចឹងដៃស្តាំរបស់គាត់ត្រូវបានមុតនឹងកាំបិត ដូច្នេះហើយធ្វើឲ្យគាត់មានការឈឺចាប់យ៉ាងខ្លាំង អញ្ចឹងនៅពេលដែលយើងកាន់កាំបិត ឬរបស់មុតស្រួចផ្សេងៗ យើងត្រូវមានការប្រុងប្រយ័ត្នជាប់ជានិច្ច បាទ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ព្រោះថាប្រសិនបើយើងមិនបានប្រុងប្រយ័ត្ននោះទេ កាំបិតឬរបស់មុតស្រួចផ្សេងៗ
អាចនឹងមុតយើងជាយថាហេតុបាន ព្រោះរបស់ស្រួចៗ និងកាំបិត គឺងាយនឹងមុតខ្លាំងណាស់ បាទ
ងាយនឹងមុតខ្លាំងណាស់ ដូច្នេះយើងត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុត ដើម្បីឲ្យកុំឲ្យមានគ្រោះថ្នាក់
ព្រោះប្រសិនបើមុត ឬមានគ្រោះថ្នាក់ យើងអាចនឹងមានការឈឺចាប់ មានឈាមហូរ
ក៏ដូចជាខាតពេលវេលានៅក្នុងការទៅមន្ទីរពេទ្យជាដើម ហើយខាតថវិកាក្នុងការព្យាបាលវា
ដូច្នេះយើងត្រូវមានការប្រុងប្រយ័ត្ននៅពេលដែលកាន់របស់ស្រួចឬមុត
ដូចជាកាំបិតនិងអំបែងជាដើម ដូចនៅក្នុងរូបភាពនេះ បុរសនេះ
គាត់ពុំបានប្រយ័ត្ននៅក្នុងការចិតបន្លែនោះទេ ដូច្នេះហើយ
បានធ្វើឲ្យកាំបិតរបស់គាត់មុតដៃស្ដាំរបស់គាត់ ដែលធ្វើឲ្យគាត់មានការឈឺចាប់យ៉ាងខ្លាំង។

ចូលមកដល់រូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា បន្ទាប់ពីគាត់បានចិតបន្លែ
ហើយកាំបិតរបស់គាត់មុតដៃស្ដាំរបស់គាត់ហើយ បុរសនោះបានសម្ដែងនូវការឈឺចាប់
ដោយទឹកមុខរបស់គាត់គឺញញៀញធ្មេញ ហើយភ្នែករបស់គាត់សម្លឹងទៅដៃស្ដាំរបស់គាត់
យើងឃើញនៅក្នុងរូបភាពនេះ គាត់បានយកដៃឆ្វេងរបស់គាត់ចាប់ដៃស្ដាំឡើង បាទ
យកដៃឆ្វេងរបស់គាត់ចាប់ដៃស្ដាំឡើង ហើយយកមកមើល អញ្ចឹងគាត់ចាប់ដៃស្ដាំឡើងបែបនេះ
គឺដើម្បីយកមកមើលមុខរបួស បាទ គាត់មើលមុខរបួសដែលមុតនឹងកាំបិត អញ្ចឹងកន្លែងដែលមុត
ឬក៏កន្លែងដែលមានគ្រោះថ្នាក់ ឬយើងហៅថាមុខរបួស ដូច្នេះហើយមុខរបួសដែលមុតដោយកាំបិត
ឬមុតដោយរបស់ស្រួចផ្សេងៗ តែងតែមានសភាពមានហូរឈាមហើយនិងឈឺចាប់
អញ្ចឹងគាត់បានមើលមុខរបួសគាត់ តើមុខរបួសគាត់ធ្ងន់ធ្ងរដែរឬទេ
ដូច្នេះហើយទើបគាត់ចាប់យកដៃឆ្វេង ចាប់ដៃស្ដាំឡើងខ្ពស់បន្តិចដើម្បីយកមកមើល
ហើយនៅក្នុងអាការៈបែបនេះគឺគាត់សម្ដែងនៅការឈឺចាប់ចំពោះដៃរបស់គាត់
ដែលបានមុតកាំបិតយ៉ាងខ្លាំង យើងឃើញថា បន្ទាប់ពីមុតដៃហើយ
បុរសនោះបានទុកកាំបិតចុះនៅលើតុ អញ្ចឹងគាត់បានទុកកាំបិតចុះនៅលើតុ
ហើយគាត់បានមើលដៃរបស់គាត់ យើងឃើញបន្លែនិងកាំបិតនៅលើតុរាយប៉ាយតែម្ដង
បានន័យថាបុរសនោះគាត់ស្លន់ស្លោ ឬគឺគាត់ភ័យ
អញ្ចឹងហើយគាត់ពុំបានរៀបចំឲ្យមានសណ្ដាប់ធ្នាប់នោះទេ ដោយសារតែគាត់មុតដៃ បាទ
អញ្ចឹងនៅក្នុងការទុកដាក់របស់ស្រួចៗឬក៏មុត យើងត្រូវមានការប្រុងប្រយ័ត្នផងដែរ
ព្រោះប្រសិនបើយើងទុកមិនមានសណ្ដាប់ធ្នាប់នោះទេ យើងអាចប៉ះរបស់នោះដោយចៃដន្យ
អញ្ចឹងនៅពេលដែលយើងប៉ះនូវរបស់នោះដោយចៃដន្យ
យើងអាចនឹងមានគ្រោះថ្នាក់ដោយសារតែរបស់នោះម្ដងទៀត ដូច្នេះដូចជានៅក្នុងរូបភាពនេះ
ប្រសិនបើគាត់ដាក់ដៃទៅលើតុវិញ នោះគាត់នឹងមុតកាំបិតម្ដងទៀតជាក់ជាមិនខាន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយសារតែគាត់ទុករបស់ឬក៏ទុកកាំបិតរបស់គាត់ មិនមានសណ្ដាប់ធ្នាប់
ឬក៏មិនបានទុកដោយមានការប្រុងប្រយ័ត្ន នៅពេលដែលគាត់មុតដៃម្ដងហើយ។

ចូលមកដល់រូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា បុរសនោះ
គាត់នៅតែសម្ដែងភាពឈឺចាប់របស់គាត់ ដោយគាត់បានបើកភ្នែកធំៗ មើលទៅលើដៃស្ដាំរបស់គាត់
ហើយគាត់នៅតែញ្ញេញធ្មេញដដែល ព្រោះថាការមុតនឹងកាំបិតគឺមានការឈឺចាប់ខ្លាំងណាស់
ដោយយើងឃើញថា នៅ ដៃស្ដាំរបស់គាត់ ដែលដាក់នៅចំពីមុខគាត់
គាត់បានលើកដៃស្ដាំដាក់នៅចំពីមុខគាត់ ហើយគាត់សម្លឹងមើល
យើងឃើញថាដៃស្ដាំរបស់គាត់គឺមានហូរឈាមចេញមកយ៉ាងច្រើន អញ្ចឹងនៅពេលដែលយើងមុត
ឬមានគ្រោះថ្នាក់ដោយសារការប៉ះពាល់របស់ស្រួចៗ ឬក៏របស់មុតដូចជាកាំបិត
នោះឈាមនឹងហូរចេញមកក្រៅយ៉ាងច្រើន ដូច្នេះហើយធ្វើឲ្យយើងមានការឈឺចាប់និងមានរបួស
អញ្ចឹងនៅក្នុងរូបភាពនេះ គាត់បានយកដៃឆ្វេងរបស់គាត់ចាប់កាន់ដៃស្ដាំ បាទ ចាប់កាន់កដៃដៃស្ដាំ
ហើយលើកដៃនោះឡើង លើកដៃស្ដាំឡើង ហើយគាត់មើល
យើងឃើញមានឈាមចេញពីម្រាមដៃនាង អញ្ចឹងម្រាមដៃរបស់យើងគឺមានម្រាមប្រាំ បាទ
មានម្រាមមេដៃ ម្រាមចង្អុលដៃ ម្រាមដៃកណ្ដាល ម្រាមដៃនាង និងម្រាមកូនដៃ អញ្ចឹងគាត់មុត
ម្រាមដៃលគាត់មុតនេះ យើងឃើញថាឈាមបានហូរចេញពីម្រាមដៃនាងដែលនៅក្បែរកូនដៃ
អញ្ចឹងម្រាមដៃនាងឈាមហូរចេញមក គឺហូរមកប្រឡាក់នឹងម្រាមដៃនាង
ក៏ដូចជាម្រាមកូនដៃផងដែរ ព្រោះម្រាមដៃនាងនិងម្រាមកូនដៃគឺនៅជិតគ្នា បាទ
ម្រាមទាំងពីរនេះគឺនៅជិតគ្នា ដូច្នេះហើយ នៅពេលដែលម្រាមដៃនាងមានឈាម
វានឹងហូរមកប្រឡាក់ម្រាមដៃកូនដូចគ្នា។

មកដល់រូបភាពទី ៥ នៅក្នុងរូបភាពទី ៥ យើងឃើញថា បន្ទាប់ពីបុរសនោះបានមុតដៃ
ហើយគាត់បានសម្លឹងមើលមុខរបួសគាត់អស់ពេលយ៉ាងយូររួច ហើយនោះ រំពេចនោះ
គាត់ក៏បានរត់ចេញពីផ្ទះបាយ អញ្ចឹងអម្បាញ់មិញគាត់ធ្វើម្ហូបនៅក្នុងផ្ទះបាយ បន្ទាប់ពីគាត់មុតដៃ
គាត់បានចេញពីក្នុងផ្ទះបាយ ហើយគាត់ចូលមកបន្ទប់ទឹក
អញ្ចឹងគាត់រត់ចូលបន្ទប់ទឹកតាមទ្វារបន្ទប់ទឹក បាទ បន្ទប់ទឹករបស់គាត់គឺមានទ្វារមួយ
ហើយនៅក្នុងបន្ទប់ទឹកនោះគឺមានបង្អួចមួយ បាទ បង្អួចកញ្ចក់
អញ្ចឹងយើងឃើញថាកញ្ចក់កំពុងតែបើក ដើម្បីឲ្យមានខ្យល់ចេញចូលនិងពន្លឺចេញចូល
ហើយនៅក្បែរកញ្ចក់នោះយើងឃើញថាមានទូមួយ ដែលកូនទូមួយនោះ គឺជាទូសម្រាប់ដាក់សម្ភារៈ
ដូចជាថ្នាំដុសធ្មេញ ថ្នាំដុសធ្មេញ សាប៊ូកក់សក់ សាប៊ូដុសខ្លួន ថ្នាំ និងបង់បិទដំបៅផ្សេងៗ
សម្រាប់ធ្វើការសង្គ្រោះបឋម អញ្ចឹងនៅពេលដែលយើងមានរបួសបន្តិចបន្តួច

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងត្រូវធ្វើការសង្គ្រោះបឋមមុននឹងទៅមន្ទីរពេទ្យ ឬក៏មុននឹងទៅកន្លែងព្យាបាល ព្រោះការសង្គ្រោះបឋមអាចធ្វើឲ្យយើងផុតគ្រោះថ្នាក់បាន ដូច្នេះបុរសម្នាក់នោះ គាត់បានរត់ចូលមកក្នុងបន្ទប់ទឹក ហើយនៅក្នុងបន្ទប់ទឹក នៅក្រោមប្រអប់សង្គ្រោះបឋមនោះ គឺមានឡាបូសម្រាប់លាងដៃមួយ ហើយនៅលើឡាបូនោះគឺមានក្បាលរ៉ូប៊ីនេសម្រាប់បង្ហូរទឹកផងដែរ អញ្ចឹងយើងឃើញថា គាត់រត់បណ្តើរ ដៃឆ្វេងរបស់គាត់ចាប់កាន់ដៃស្តាំបណ្តើរ អញ្ចឹងគាត់ចាប់កាន់ដៃស្តាំដែលមុតបណ្តើរ ហើយរត់ចូលក្នុងបន្ទប់ទឹក យើងឃើញថាឈាមកំពុងតែស្រក់ចេញពីម្រាមដៃរបស់គាត់ ឈាមកំពុងតែស្រក់ចេញពីម្រាមដៃរបស់គាត់ផងដែរ។

ចូលមកដល់រូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថា បន្ទាប់ពីបុរសនោះបានចូលមកដល់បន្ទប់ទឹកហើយ គាត់បានរត់សំដៅមករកឡាបូលាងដៃ អញ្ចឹងគាត់រត់មករកឡាបូលាងដៃ ដោយនៅក្នុងឡាបូលាងដៃនេះ យើងឃើញថានៅខាងលើឡាបូ គឺមានក្បាលរ៉ូប៊ីនេទឹកមួយ គាត់បានបើករ៉ូប៊ីនេទឹកនោះ ដើម្បីឲ្យទឹកហូរចេញមក បាទ គាត់បើកទឹកដើម្បីឲ្យទឹកហូរចេញ ហើយគាត់ដាក់ដៃទៅក្រោមទឹកនោះដើម្បីលាងសម្អាតដៃ អញ្ចឹងនៅពេលដែលយើងមានរបួស ហើយធ្វើឲ្យមានការហូរឈាម ឬក៏ដាច់រលាត់ស្បែកផ្សេងៗ យើងត្រូវធ្វើការលាងសម្អាតមុខរបួសនោះឲ្យបានស្អាត ប្រសិនបើយើងមិនលាងសម្អាតនោះទេ មេរោគនឹងអាចជ្រាបចូលក្នុងខ្លួនរបស់យើងតាមរយៈមុខរបួសនោះជាក់ជាមិនខាន ដូច្នេះបុរសនោះ គាត់ត្រូវលាងដៃរបស់គាត់ដែលមានមុខរបួសឲ្យបានស្អាតជាមុនសិន មុននឹងធ្វើការព្យាបាល ធ្វើ[យ៉ាង]នេះគឺមេរោគមិនអាចចូលមកក្នុងខ្លួនតាមរយៈមុខរបួសបានទេ អញ្ចឹងនៅក្នុងរូបភាពនេះ គាត់លាងដៃរបស់គាត់ ដោយគាត់លាងឈាម ក៏ដូចជាមេរោគនៅក្បែរដៃរបស់គាត់ឲ្យបានស្អាតសិន។

នៅក្នុងរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា បន្ទាប់ពីលាងដៃរួចហើយ បុរសម្នាក់នោះ គាត់បានយកសំឡីមួយដុំ បាទ សំឡីមួយដុំ សំឡីគឺមានពណ៌ស អញ្ចឹងគាត់បានយកសំឡីមក ហើយគាត់បានយកខ្ទប់ ខ្ទប់ទៅនឹងមុខរបួសរបស់គាត់ ឬក៏ខ្ទប់ទៅនឹងដៃស្តាំដែលមានរបួស អញ្ចឹងគាត់យកសំឡីមក ដើម្បីខ្ទប់ទៅមុខរបួសកុំឲ្យហូរឈាម ហើយគាត់ជូតឈាមនោះចេញ យើងឃើញថានៅក្នុងរូបភាពនេះ គាត់បានធ្វើមុខជូរ បាទ បុរសនោះគាត់ធ្វើមុខជូរ ដោយបើកភ្នែកតូចៗ ហើយមាត់គាត់ស្រួច អញ្ចឹងគាត់ធ្វើមុខបែបនេះគឺបានន័យថាមុខជូរ គឺបានន័យថាគាត់កំពុងតែឈឺ អញ្ចឹងហើយគាត់បានយកសំឡីមកជូតឈាមចេញ ដើម្បីកុំឲ្យប្រឡាក់ដៃគាត់ទៀត ហើយគាត់យកសំឡីនោះទៅខ្ទប់លើមុខរបួសដើម្បីឃាត់ឈាម អញ្ចឹងនៅពេលដែលយើងមុតដៃ កុំ យើងមិនត្រូវប្រើប្រាស់របស់ដែលកខ្វក់នោះទេ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងត្រូវប្រើសំឡី ឬក្រណាត់ដែលស្អាត ដើម្បីជូតឈាមចេញ
ព្រោះថានៅពេលដែលយើងប្រើប្រាស់របស់កខ្វក់ មេរោគដែលនៅរបស់កខ្វក់នោះ
អាចនឹងជ្រាបចូលក្នុងខ្លួនរបស់យើងតាមរយៈមុខរបួស ដូច្នេះហើយយើងត្រូវធ្វើតាមបុរសម្នាក់នេះ
បាទ បុរសម្នាក់នេះ គាត់បានយកសំឡីមកខ្ទប់មុខរបួស ហើយនិងឃាត់ឈាម ដើម្បីកុំឲ្យឈាមហូរ
ធ្វើបែបនេះគឺការរក្សាអនាម័យខ្លួនប្រាណរបស់គាត់កុំឲ្យមានមេរោគ។

ចូលមកដល់រូបភាពទី ៨ រូបភាពទី ៨ យើងឃើញថាបុរសម្នាក់នោះកាន់សំឡីនៅដៃឆ្វេងរបស់គាត់
បាទ ដៃឆ្វេងរបស់គាត់កាន់សំឡី រីឯដៃស្ដាំរបស់គាត់លើកឡើង
បានន័យថាគាត់បានជូតឈាមចេញពីដៃស្ដាំរបស់គាត់អស់ហើយ អញ្ចឹងយើងឃើញថា
ដៃស្ដាំរបស់គាត់គឺមានស្នាមមុខរបួសនៅនឹងម្រាមដៃនាង បាទ
នៅនឹងម្រាមដៃនាងរបស់គាត់គឺមានស្នាមមុខរបួស ប៉ុន្តែពុំមានឈាមហូរទៀតទេ បាទ
ពុំមានឈាមហូរទេ អញ្ចឹងឈាមឈប់ហូរហើយដោយសារតែគាត់ជូតឈាមនោះចេញ
ហើយគាត់បានយកសំឡីខ្ទប់ទៅលើមុខរបួសដើម្បីឃាត់ឈាម បន្ទាប់ពីឃាត់ឈាម
ឈាមក៏ឈប់ហូរ ពេលនោះ បុរសនោះ គាត់បានប្រែប្រួលទឹកមុខរបស់គាត់ ដោយគាត់
មុខគាត់រៀងញញឹមបន្តិច បាទ ពីមុនគាត់មានមុខជូរ ដោយសារគាត់ឈឺ ហើយមានឈាមហូរ
ក៏ប៉ុន្តែបន្ទាប់ពីគាត់ឃាត់ឈាមហើយ គាត់ក៏ប្រែទឹកមុខមកជាញញឹមវិញ ព្រោះថាគាត់សប្បាយចិត្ត
ដោយសារតែមុខរបួសរបស់គាត់លែងមានឈាមហូរទៀតហើយ
ដូច្នេះវាមិនមានគ្រោះថ្នាក់ខ្លាំងនោះទេទៅដល់គាត់ ព្រោះគាត់បានឃាត់ឈាមបានសម្រេច។

នៅក្នុងរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា បុរសម្នាក់នោះ
បន្ទាប់ពីគាត់ឃាត់ឈាមហើយ បាទ គាត់ឃាត់ឈាមរួចហើយ គាត់ក៏បានបើកទូ
ដែលនៅលើឡាបូលាងដៃនោះ បាទ កូនទូនោះគឺមានដូចជាច្រាសដុសធ្មេញ ថ្នាំដុសធ្មេញ
សាប៊ូលាងដៃ សាប៊ូកក់សក់ សាប៊ូដុសខ្លួនជាដើម ហើយនៅក្នុងនោះយើងឃើញថា
គាត់បានទាញយកនូវប្រអប់មួយ បាទ ទាញប្រអប់មួយចេញពីទូនោះ ដោយប្រអប់នោះ
គឺជាប្រអប់នៃបង់បិទដំបៅ បាទ គាត់យកប្រអប់នៃបង់បិទដំបៅចេញមក
អញ្ចឹងគាត់បានយកបង់បិទដំបៅនោះមកចាក់លើបាតដៃ
យើងឃើញថាបង់បិទដំបៅចេញពីប្រអប់នោះមានចំនួនមួយ អញ្ចឹងបានន័យថា[ប្រអប់]
បង់បិទដំបៅរបស់គាត់នៅសល់តែមួយនោះទេ បាទ បង់បិទដំបៅគឺយើងយកមក
ដើម្បីរុំលើមុខរបួស ដើម្បីកុំឲ្យមានមេរោគចូល ព្រោះថា
ទោះបីជាយើងជូតមុខរបួសស្អាតហើយក៏ដោយ ក៏ប៉ុន្តែប្រសិនបើយើងមិនរុំវាឲ្យបានជិតល្អនោះទេ
មេរោគនឹងជ្រាបចូលជាក់ជាមិនខាន ព្រោះថាមេរោគនៅក្នុងបរិយាកាស

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះប្រសិនបើយើងមិនបានរុំរបួស មេរោគនឹងចូលក្នុងខ្លួនយើងតាមរយៈរបួសនោះមិនខាន អញ្ចឹងក្នុងការរុំរបួស យើងត្រូវតែប្រើប្រាស់នៅរបស់ស្អាត ដូចជាបង់បិទដំបៅ ឬក៏ក្រណាត់ស្អាត ព្រោះថារបស់ទាំងពីរនេះ គឺអាចការពារមេរោគបាន ប៉ុន្តែប្រសិនបើយើងយករបស់មិនស្អាត មកធ្វើការរុំរបួស នោះមេរោគនឹងចូលមកខ្លួនយើងតាមរយៈមុខរបួសនោះ នៅក្នុងរូបភាពនេះ បុរសនោះ គាត់បានយកបង់បិទដំបៅ ដើម្បីយកមករុំរបួសគាត់ អញ្ចឹងយើងឃើញគាត់ចាក់បង់បិទដំបៅចេញពីក្នុងប្រអប់។

នៅក្នុងរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា បន្ទាប់ពីគាត់ចាក់បង់បិទដំបៅចេញពីក្នុងប្រអប់មក គឺបង់បិទដំបៅនោះនៅសល់តែមួយតែប៉ុណ្ណោះ ដោយគាត់បានលើកប្រអប់ឡើង ដើម្បីបើកភ្នែកមើលទៅក្នុងប្រអប់នោះ យើងឃើញក្នុងរូបភាពនេះ ដៃឆ្វេងរបស់គាត់កាន់ប្រអប់បង់បិទដំបៅឡើងកម្ពស់នឹងភ្នែក ហើយគាត់បិទភ្នែកម្ខាង បើកភ្នែកម្ខាង អញ្ចឹងបានគាត់បិទភ្នែកម្ខាង បើកភ្នែកម្ខាង ហើយភ្នែកដែលបើកនោះ គឺសម្លឹងចូលទៅមើលក្នុងប្រអប់ គឺធ្វើបែបនេះដើម្បីគាត់ពិនិត្យមើលថា តើបង់បិទដំបៅអស់ហើយឬនៅ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា បង់បិទដំបៅនៅសល់តែមួយ ដោយគាត់ នៅសល់តែមួយ ដោយគាត់កាន់នៅនឹងដៃស្តាំ ហើយនៅក្នុងប្រអប់គឺពុំមានបង់បិទដំបៅសល់ទៀតនោះទេ។

ចូលដល់រូបភាពទី ១០ រូបភាពទី ១១ នៅក្នុងរូបភាពទី ១១ យើងឃើញថា បុរសម្នាក់នោះ បន្ទាប់ពីយកបង់បិទដំបៅបានហើយ គាត់ក៏ចាប់ផ្តើមបក អញ្ចឹងបង់បិទដំបៅគឺមានសភាពស្អិត បាទ បង់បិទដំបៅគឺមានសភាពស្អិត ដើម្បីឲ្យរុំជាប់ជាមួយនឹងដៃ ដូច្នេះដើម្បីការពារសភាពស្អិតនោះ កុំឲ្យស្អិតទៅនឹងវត្ថុផ្សេងៗ បង់បិទដំបៅគឺគេគ្របទៅដោយប្លាស្ទិកមួយ អញ្ចឹងគេគ្របទៅដោយប្លាស្ទិក អញ្ចឹងមុននឹងយើងអាចប្រើប្រាស់បង់បិទដំបៅនោះបាន ឬក៏យកមកបិទលើមុខរបួសបាន យើងត្រូវបកប្លាស្ទិកនោះចេញ នៅក្នុងរូបភាពទី ១១ នេះ យើងឃើញថា បង់បិទដំបៅគឺមានពណ៌ប្រផេះ បាទ បង់បិទដំបៅគឺមានពណ៌ប្រផេះ ហើយប្លាស្ទិកដែលគ្របពីលើបង់បិទដំបៅនៅកន្លែងស្អិតនោះគឺមានពណ៌ស អញ្ចឹងគេយកប្លាស្ទិកពណ៌ស គ្របបិទពីលើកន្លែងដែលស្អិតនៃបង់បិទដំបៅ បាទ ដើម្បីកុំឲ្យបង់បិទដំបៅស្អិតទៅកន្លែងផ្សេងទៀត អញ្ចឹងដើម្បីប្រើប្រាស់បាន បុរសនោះ គាត់បានយកដៃរបស់គាត់បកនូវប្លាស្ទិកពណ៌សនោះចេញ បាទ នៅក្នុងរូបភាពនេះ គឺគាត់កំពុងតែបកប្លាស្ទិកពណ៌សចេញពីកន្លែងស្អិតនៃបង់បិទដំបៅ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ចូលដល់រូបភាពទី ១២ នៅក្នុងរូបភាពទី ១២ បន្ទាប់ពីបុរសនោះ
គាត់បានបកប្លាស្ទិកចេញពីកន្លែងស្អិតនៃបង់បិទដំបៅហើយ គាត់បានយកបង់បិទដំបៅនោះ
មករុំលើដៃ ម្រាមដៃនាងរបស់គាត់ អញ្ចឹងយើងឃើញថា នៅក្នុងរូបភាពនេះគឺមានដៃចំនួនពីរ
ដៃឆ្វេងមួយនិងដៃស្តាំមួយ ហើយដៃដែលមានរបួសគឺដៃស្តាំ ម្រាមនាងដៃ
អញ្ចឹងម្រាមនាងដៃរបស់គាត់គឺមានមុខរបួសដោយសារមុតកាំបិត ដូច្នេះគាត់យកបង់បិទដំបៅ
ដែលគាត់ទើបតែបករួចនោះ មក គាត់យកបង់បិទដំបៅដែលទើបតែបករួចនោះ
មកបិទពីលើដៃនាងរបស់គាត់ គឺបិទពីលើមុខរបួសតែម្តង បាទ ធ្វើបែបនេះ
ដើម្បីការពារកុំឲ្យមុខរបួសរបស់គាត់មានមេរោគចូល បាទ
ធ្វើកុំឲ្យមានមេរោគចូលក្នុងមុខរបួសរបស់គាត់។

ចូលមកដល់រូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញថា បុរសនោះ
គាត់បានប្រែប្រួលទឹកមុខរបស់គាត់ទៅជាសប្បាយចិត្តវិញ បាទ យើងឃើញថា គាត់ហាមាត់ញញឹម
គាត់ញញឹម មើលទៅលើដៃស្តាំរបស់គាត់ អញ្ចឹងដៃស្តាំរបស់គាត់គឺមានរបួស
ក៏ប៉ុន្តែរបួសរបស់គាត់បានរុំនឹងបង់បិទដំបៅរួចហើយ ដូច្នេះបានន័យថាគាត់បានការពារដៃរបស់គាត់
កុំឲ្យមានមេរោគចូលរួចហើយ ហើយឈាមរបស់គាត់ក៏ឈប់ហូរទៀតដែរ
អញ្ចឹងគាត់នឹងលែងមានគ្រោះថ្នាក់ទៀតហើយ ដូច្នេះគាត់បានមើលដៃរបស់គាត់
ហើយគាត់សប្បាយចិត្តយ៉ាងខ្លាំង ដោយគាត់គិតថា
គាត់មិនមានគ្រោះថ្នាក់អ្វីធ្ងន់ធ្ងរនោះទេបន្ទាប់ពីការមុតកាំបិតនេះ
ព្រោះគាត់បានធ្វើចេះវិធីសង្គ្រោះបឋម បាទ គាត់ចេះវិធីសង្គ្រោះបឋម
ដើម្បីកុំឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ។

បន្ទាប់ពីបានរុំដៃហើយ នៅក្នុងរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤
បន្ទាប់ពីគាត់រុំដៃគាត់នឹងបង់បិទដំបៅរួចហើយ បុរសនោះ គាត់ក៏បានចូលមកក្នុងផ្ទះបាយវិញ បាទ
គាត់ចូលមកក្នុងផ្ទះបាយវិញ គាត់ចូលមកដើម្បីបន្តការចិតបន្លែធ្វើម្ហូបរបស់គាត់បន្តទៀត បាទ
អញ្ចឹងបុរសនោះ គាត់កាន់ការ៉ុតដដែល បាទ គាត់កាន់ការ៉ុត
ហើយចិតចំណិតការ៉ុតនោះជាចំណិតតូចៗជាច្រើនដាក់នៅលើតុ បាទ
ម្តងនេះគឺគាត់មានការប្រុងប្រយ័ត្នខ្ពស់ជាងមុន បាទ ព្រោះថាយើងឃើញថា
ដៃរបស់គាត់កាន់កាំបិតដោយប្រុងប្រយ័ត្ន ហើយដៃម្ខាងទៀតរបស់គាត់ដែលកាន់ការ៉ុត
ក៏មានការប្រុងប្រយ័ត្នដែរ ព្រោះថាគាត់មិនធ្វើឲ្យមានការមុតដៃជាលើកទីពីរទៀតនោះទេ
ព្រោះការមុតដៃគឺវាធ្វើឲ្យឈឺ ហើយមានគ្រោះថ្នាក់ អញ្ចឹងគាត់ធ្វើការប្រុងប្រយ័ត្នខ្ពស់ជាងមុន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅក្នុងរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញថា បន្ទាប់ពីបុរសនោះបានធ្វើម្ហូបរួចរាល់ហើយ បាទ បុរសម្នាក់នោះ គាត់ធ្វើម្ហូបរួចរាល់ហើយ គាត់ក៏បាននឹកឃើញទៅដល់បង់បិទដំបៅដែលអស់ បាទ អញ្ចឹងហើយគាត់ក៏បានយកប្រអប់បង់បិទដំបៅមកចាក់មើលម្តងទៀតថាតើវាអស់ហើយឬនៅ បាទ នៅក្នុងរូបភាពនេះ គាត់យកដៃឆ្វេងរបស់គាត់កាន់បង់បិទដំបៅ កាន់ប្រអប់បង់បិទដំបៅ លើកឡើងលើ ហើយចាក់ចុះក្រោម អញ្ចឹងមាត់បង់បិទដំបៅគឺចាក់ចុះក្រោម ដើម្បីឲ្យបង់បិទដំបៅធ្លាក់ ក៏ប៉ុន្តែពុំមានបង់បិទដំបៅធ្លាក់នោះទេ ដូច្នេះហើយគាត់ក៏បានគិតទៅដល់បង់បិទដំបៅថាតើវាអស់ហើយឬនៅ អញ្ចឹងគាត់បានសួរខ្លួនឯងថា បង់បិទដំបៅនេះអស់ហើយឬនៅ យើងឃើញបង់បិទដំបៅដែលគាត់កំពុងតែគិត ហើយមានសញ្ញាសួរនៅក្បែរនោះ អញ្ចឹងបានន័យថា នៅពេលដែលគាត់ចាក់បង់បិទដំបៅចេញពីប្រអប់[...] មិនមានចេញនោះទេ បានន័យថាបង់បិទដំបៅរបស់គាត់អស់ហើយ។

នៅក្នុងរូបភាពទី ១៦ រូបភាពទី ១៦ បន្ទាប់ពីបង់បិទដំបៅរបស់គាត់អស់ បុរសនោះក៏គាត់បានដើរទៅហ្វាម៉ាស៊ី បាទ ឬក៏ឱសថស្ថាន អញ្ចឹងនៅក្នុងប្រទេសកម្ពុជា កន្លែងដែលមានលក់បង់បិទដំបៅគឺមានដូចជាឱសថស្ថាន ឬក៏មន្ទីរពេទ្យ ឬក៏តូបលក់ចាប់ហួយផ្សេងៗ អញ្ចឹងនៅក្នុងតូបលក់ចាប់ហួយក៏មានលក់បង់បិទដំបៅដែរ ហើយនៅក្នុងរូបភាពនេះ គឺឃើញថាគាត់បានដើរទៅដល់កន្លែងលក់ថ្នាំមួយ បាទ កន្លែងលក់ថ្នាំ យើងហៅថាឱសថស្ថាន យើងអាចហៅបានពីរ ហ្វាម៉ាស៊ី ឬក៏ឱសថស្ថាន បាទ កន្លែងទាំងពីរនេះ គឺជាកន្លែងដែលលក់ថ្នាំពេទ្យ និងលក់សម្ភារៈវេជ្ជសាស្ត្រ ឬក៏សម្ភារៈពេទ្យ អញ្ចឹងគាត់ដើរទៅទីនោះ យើងឃើញនៅក្នុងរូបភាពនេះ គឺនៅ នៅមាត់ទ្វាររបស់ឱសថស្ថាននោះ គឺមានផ្លាកសញ្ញាបូកមួយ បាទ ផ្លាកសញ្ញាបូក អញ្ចឹងសញ្ញាពេទ្យ ឬក៏សញ្ញាសង្គ្រោះ គឺមានសញ្ញាបូកពណ៌ក្រហម ផ្ទៃពណ៌ស អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថាទ្វារ នៅ នៅខាងលើទ្វារចូល គឺយើងឃើញមានសញ្ញាបូកពណ៌ក្រហមនៅលើផ្ទៃពណ៌ស ដូច្នេះបានន័យថាសញ្ញានេះ គឺជាសញ្ញាពេទ្យ បាទ បុរសនោះ គាត់បានដើរទៅដល់ឱសថស្ថាន ឬក៏ទៅដល់ពេទ្យនោះ។

នៅក្នុងរូបភាពទី ១៧ បាទ ចូលដល់នៅក្នុងរូបភាពទី ១៧ វិញ បុរសម្នាក់នោះបានជួបជាមួយនឹងអ្នកលក់ បាទ ជួបជាមួយនឹងអ្នកលក់ ឬក៏គ្រូពេទ្យ ឬក៏ម្ចាស់ឱសថស្ថាន អញ្ចឹងគាត់ជួបហើយ គាត់បាននិយាយទៅកាន់ម្ចាស់ឱសថស្ថាននោះថា គាត់ត្រូវការបង់បិទដំបៅមួយប្រអប់ បាទ អញ្ចឹងយើងឃើញនៅ នៅពីលើបុរសនោះ គឺមានបង់បិទដំបៅជាច្រើន អញ្ចឹងបានន័យថាគាត់កំពុងតែនិយាយទៅកាន់ម្ចាស់ឱសថស្ថាន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏គ្រូពេទ្យថាគាត់ចង់ទិញបង់បិទដំបៅ បាទ ចំណែកម្ចាស់ឱសថស្ថានវិញ យើងឃើញថា
គាត់ពាក់អាវសដៃខ្លី ហើយមានចងអៀមពណ៌ទឹកសមុទ្រ អញ្ចឹងគាត់ពាក់អាវសដៃខ្លី
ចងអៀមពណ៌ទឹកសមុទ្រ ចំណែកសក់របស់គាត់គឺទំពែក អញ្ចឹងគាត់ទំពែកក្បាល
គាត់មានសក់តែខាងក្រោយតែប៉ុណ្ណោះ យើងឃើញនៅក្នុងដៃរបស់ម្ចាស់ឱសថស្ថាន
ឬក៏គ្រូពេទ្យនោះ គឺមានកាន់បង់បិទដំបៅមួយប្រអប់ អញ្ចឹងបុរសនោះ គាត់ទិញបង់បិទដំបៅ
ដូច្នេះហើយ ទើបម្ចាស់ឱសថស្ថាន គាត់យកបង់បិទដំបៅឲ្យទៅបុរសនោះ
អញ្ចឹងពួកគេទាំងពីរនាក់គឺ គឺកំពុងតែធ្វើការទិញ ទិញលក់គ្នានូវបង់បិទដំបៅ
ដូច្នេះម្ចាស់ឱសថស្ថានត្រូវប្រគល់បង់បិទដំបៅទៅឲ្យបុរសនោះ ចំណែកបុរសនោះ
គាត់ត្រូវប្រគល់លុយថ្លៃបង់បិទដំបៅទៅឲ្យម្ចាស់ឱសថស្ថានវិញ អញ្ចឹងរាល់ការទិញលក់
យើងត្រូវប្រគល់ទំនិញនិងប្រគល់លុយទៅឲ្យគ្នាទៅវិញទៅមក
ដូចជាការទិញនៅក្នុងឱសថស្ថាននេះអញ្ចឹង
ហើយឱសថស្ថានគឺយើងមិនមែនលក់តែបង់បិទដំបៅតែមួយមុខនោះទេ ក៏ប៉ុន្តែយើងលក់ជាច្រើន
ដូចជាថ្នាំ ដូចជាបង់បិទដំបៅ ដូចជាសេរ៉ូម ដូចជាម្សុលចាក់ថ្នាំជាដើម។ អញ្ចឹងសម្ភារៈរបស់ពេទ្យ
ឬក៏សម្ភារៈវេជ្ជសាស្ត្រមានលក់នៅក្នុងឱសថស្ថាន បាទ អញ្ចឹងពេលយើង ពេល
នៅពេលដែលយើងចង់ទិញថ្នាំ ឬក៏ចង់ទិញបង់បិទដំបៅផ្សេងៗ យើងត្រូវទៅរកឱសថស្ថាន
ដើម្បីឲ្យគេផ្សំថ្នាំឲ្យ បាទ ចំពោះការផ្សំថ្នាំ ទៀតសោត គឺយើងមិនត្រូវផ្សំផ្តេសផ្តាសនោះទេ
គឺយើងត្រូវផ្សំតាមវេជ្ជបញ្ជារបស់ពេទ្យ អញ្ចឹងការណែនាំរបស់ពេទ្យគេហៅថាវេជ្ជបញ្ជា
ដូច្នេះនៅពេលដែលយើងឈឺ យើងត្រូវទៅពេទ្យ បន្ទាប់មកយកវេជ្ជបញ្ជា
ដើម្បីមកផ្សំថ្នាំនៅតាមឱសថស្ថានដែលស្របច្បាប់នានា
ដើម្បីព្យាបាលជំងឺយើងឲ្យបានជាសះស្បើយ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.